ធនាគារជាតិ នៃ កម្ពុជា

លេខ..................................................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជា បានបន្តកម្មវិធីសន្និសីទរបស់ខ្លួនលើកិច្ចពិភាក្សាប្រធានបទសំខាន់ៗចំនួន ៤ បន្ថែមទៀតគឺ ៖ ការឲ្យខ្ចីក្នុងនិងក្រៅប្រព័ន្ធ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន សេវាធនាគារចល័ត និងតួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងសកម្មភាពសង្គម និងបរិស្ថាន ។ បន្ទាប់ពីការពិភាក្សាលើប្រធានបទនីមួយៗ អង្គសន្និសីទបានលើកនូវអនុសាសន៍ល្អៗមួយចំនួន ដូចខាងក្រោម ៖

១. ភាគីទាំងអស់បន្តជំរុញសេវាហិរញ្ញវត្ថុផ្សេងទៀតបន្ថែមលើសេវាឥណទាន តាមរយៈការពង្រីកសេវាធានារ៉ាប់រងខ្នាតតូច និងសេវាធនាគារចល័ត ជាដើម ។

២. ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងភាគីពាក់ព័ន្ធទាំងអស់ បន្តចាត់វិធានការម៉ឺងម៉ាត់ចំពោះអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកឲ្យខ្ចីចងការក្រៅផ្លូវការ ដែលធ្វើប្រតិបត្តិការធនាគារដោយពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

៣. ធនាគារជាតិនៃកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សមាគមមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា បន្តសហការលើកកម្ពស់កម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុដល់ប្រជាជន ។

៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្តល់ឥណទានផ្អែកលើសមត្ថភាពនៃការសងត្រលប់ និងផលិតភាពនៃមុខរបរឬអាជីវកម្មរបស់អតិថិជន និងត្រូវចៀសវាងការផ្តល់ឥណទានដែលមានភាពធូរលុង និងពឹងផ្អែកតែទៅលើទ្រព្យធានា ។

៥. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវពង្រឹងយន្តការនៃកិច្ចការពារអតិថិជន ដោយផ្តោតលើការអនុវត្តក្រមប្រតិបត្តិ តម្លាភាព ការបង្ហាញព័ត៌មាន ភាពសមស្របនៃផលិតផល និងគោលការណ៍និងយន្តការដោះស្រាយបណ្តឹងដែលសាមញ្ញនិងងាយស្រួល ។

៦. ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ត្រូវសហការគ្នាជំរុញការប្រើប្រាស់និងការពារហានិភ័យនៃសេវាធនាគារចល័ត តាមរយៈការអប់រំផ្តល់ចំណេះដឹងដល់អតិថិជន ការបង្កើតផលិតផលថ្មីនិងការច្នៃប្រឌិតបន្ថែមទៀត ការរក្សាសុវត្ថិភាពទិន្នន័យអតិថិជន និងការពង្រឹងក្របខណ្ឌបទប្បញ្ញត្តិ ។

៧. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបន្តរក្សាបេសកកម្មផ្នែកសង្គមនិងបរិស្ថាន ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍ ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ថ្លែងក្នុងកម្មវិធីបិទសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា ធនាគារជាតិនៃកម្ពុជាប្តេជ្ញាអនុវត្តតាមអនុសាសន៍ ដ៏ថ្លៃថ្លារបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី ព្រមទាំងទទួលយកនូវយោបល់នានាបន្ថែមទៀត ដែលបានលើកឡើង និងពិភាក្សានៅក្នុងអង្គសន្និសីទនេះ ដើម្បីរៀបចំជាទិសដៅនិងផែនការសកម្មភាពបន្ថែមទៀត សម្រាប់បន្តគាំទ្រដល់ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ។ ឯកឧត្តម ទេសាភិបាល ក៏បានផ្តាំផ្ញើដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យចូលរួមអនុវត្តតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ព្រមទាំងយោបល់នានាដែលបានលើកឡើងនៅក្នុងអង្គសន្និសីទនេះ ដើម្បីរៀបចំជាទិសដៅ និងផែនការសកម្មភាព សម្រាប់បន្តគាំទ្រដល់ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបន្ថែមទៀត ។